00637102 E18/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 01 / 2011
ម៉ោង (Time/Heure): 15:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខៈ ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

ចំពោះមុខៈ
ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម **Silvia CARTWRIGHT**
ចៅក្រម **យ៉ា សុខន**
ចៅក្រម **Jean-Marc LAVERGNE**
ចៅក្រម **ឌូ មណី**

កាលបរិច្ឆេទៈ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១
ភាសាដើមៈ ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារៈ សាធារណៈ

# ដីកាកំណត់កាលបរិច្ឆេទសវនាការទាក់ទងនឹងសំណើសុំដោះលែងឲ្យមានសេរីភាព យោងតាមវិធាន ៨២(៣) នៃវិធានផ្ទៃក្នុង

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**
សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅសៀង
Diana ELLIS
ស សុវ៉ាន
Jaques VERGÈS
Philippe GRÉCIANO

00637103



**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក អនុលោមតាមសាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ[1] ដែលបានចេញដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។

**បានឃើញ** សំណើសុំដោះលែងឱ្យមានសេរីភាព យោងតាមវិធាន ៨២(៣) នៃវិធានផ្ទៃក្នុង ដែលបានដាក់ដោយមេធាវីការពារក្ដី ខៀវ សំផន ("មេធាវី") កាលពីថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១១ ("សំណើ")។

**អនុលោម** តាមវិធាន ៧៩ និងវិធាន ៨២ នៃវិធានផ្ទៃក្នុង។

**ហេតុដូច្នេះសម្រេច**

**ទទួល** យកសំណើសុំរបស់មេធាវីការពារក្ដីដើម្បីដាក់ដេញដោលនៅក្នុងសវនាការផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ នៅបន្ទប់សវនាការធំនៃ អ.វ.ត.ក ចាប់ពីម៉ោង ១ និង ៣០ នាទីរសៀលតទៅ។

**ស្នើឲ្យ** សហព្រះរាជអាជ្ញាឆ្លើយតបដោយផ្ទាល់មាត់ទៅនឹងសំណើរបស់មេធាវីការពារក្ដីនៅក្នុងអំឡុងពេលសវនាការ ប្រសិនបើសហព្រះរាជអាជ្ញាមានបំណងធ្វើដូច្នេះ។ បន្ទាប់មក មេធាវីការពារក្ដីនឹងត្រូវអនុញ្ញាតឱ្យធ្វើការឆ្លើយតបភ្លាម។

---

[1] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/1/26។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/2/12។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/4/14។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេច បន្តថិរវេលានៃការឃុំខ្លួនគាត់បណ្ដោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/5/9។



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E C C C E T C

កត់សម្គាល់ថា វិធាន ៨២(៣) នៃវិធានផ្ទៃក្នុងកំណត់ការចូលរួមសវនាការត្រឹមតែភាគីដែលពាក់ព័ន្ធនឹងសំណើសុំប៉ុណ្ណោះ។ វិធាននេះមិនតម្រូវឱ្យមានការធ្វើការកត់សម្គាល់ពីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយក៏មិនតម្រូវឱ្យមានវត្តមានពួកគេក្នុងសវនាការដែរ។

ភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

និល ណុន